## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
## ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# អាជ្ញាប័ណ្ណរួមសម្រាប់ធ្វើសេវាកម្មផលិតនិងចែកចាយ អគ្គិសនីនៅផ្នែកខ្លះនៃសង្កាត់ក្រាំងពង្រ និងសង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ

# CONSOLIDATED LICENSE FOR PROVIDING ELECTRIC POWER GENERATION AND DISTRIBUTION SERVICES SOME PARTS OF SANGKAT KRANGPONGRO AND SANGKAT BRATEHLANG, KHAN DANGKOR, PHNOM PENH

**ក្រុមហ៊ុន វឌ្ឍនៈ ប្របតើធី អិលធីឌី**

**VATTANAC PROPERTIES LTD**

**ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១**

**OCTOBER 26, 2011**

# ផ្នែកទី១
# សេចក្តីសម្រេចផ្តល់សិទ្ធិឱ្យធ្វើសេវាកម្ម

# PART 1

# DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ -១១.អអក

# ឯកសារអាជ្ញាប័ណ្ណលេខ ៣២៥ ឯអ
# LICENSE DOCUMENT No. 325 LD

# អាជ្ញាប័ណ្ណរួមសម្រាប់ក្រុមហ៊ុន វឌ្ឍនៈ ប្របភើធី អិលធីឌី
# CONSOLIDATED LICENSE FOR VATTANAC PROPERTIES LTD

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated February 2, 2001.

-យោងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ៩៦៦ ឧរថ អកថ.ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១០

- In accordance with PRAKAS of Ministry of Industry, Mines and Energy N° 966 dated December 02, 2010.

-យោងតាមពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន វឌ្ឍនៈ ប្របភើធី អិលធីឌី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០

- In accordance with the application for License of Vattanac Properties LTD dated December 21, 2010.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកស្នើសុំអាជ្ញាប័ណ្ណ ស្ថាប័នពាក់ព័ន្ធ និងសាធារណជន ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១១

- In accordance with the consultations with the applicant, concerned parties and public, made from March 17, 2011 to April 15, 2011.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ២១៨ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១

- In accordance with the decision of Electricity Authority of Cambodia’s Session No. 218 , dated October 26 , 2011.

# សម្រេច
# DECIDES

**ប្រការ១**

ផ្តល់អាជ្ញាប័ណ្ណរួមជូនក្រុមហ៊ុន **វឌ្ឍនៈ ប្រូបភើធី អិលធីឌី** (បន្ទាប់ពីនេះហៅថា " **អ្នកកាន់អាជ្ញាប័ណ្ណ**" ) មានទីស្នាក់ការនៅផ្ទះលេខ៤៣$E_2$ ផ្លូវលេខ២៨៦ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន រាជធានីភ្នំពេញដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ Inv.១០១៣/០៥P ចុះថ្ងៃ ទី០៥ ខែធ្នូ ឆ្នាំ២០០៥ ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហគ្រាសក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណសម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅក្នុងតំបន់អនុញ្ញាត ដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ សម្រាប់ផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណដូចខាងក្រោម ៖

(ក) ធ្វើសេវាកម្មផលិតកម្មអគ្គិសនីនៅភូមិប្រទះឡាង សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យប្រព័ន្ធចែកចាយរបស់ខ្លួនតាមមធ្យោបាយផលិតកម្មដែលកំណត់ក្នុងឧបសម្ព័ន្ធទី២ ក្នុងរយៈពេលដែល កំណត់ដោយប្រការ៣ ផ្នែកទី១ខាងក្រោម ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានាដែលមានចែងក្នុងផ្នែកទី២នៃអាជ្ញាប័ណ្ណនេះ។

(ខ) ធ្វើសេវាកម្មចែកចាយ និងលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ក្នុងតំបន់ចែកចាយដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ ផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះក្នុងរយៈពេលដែលកំណត់ដោយប្រការ៣ ផ្នែកទី១ ខាងក្រោមដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានាដែលមានចែងក្នុងផ្នែកទី២ នៃអាជ្ញាប័ណ្ណនេះ ដោយទិញអគ្គិសនីពីអគ្គិសនីកម្ពុជា ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀង លក់-ទិញអគ្គិសនីរវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន វឌ្ឍនៈ ប្រូបភើធី អិលធីឌី ដែលបានចុះហត្ថលេខានៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១១ និង/ឬ ផលិតអគ្គិសនីដោយមធ្យោបាយផលិតកម្មផ្ទាល់ខ្លួនដូចបានបញ្ជាក់ក្នុងចំណុច (ក)ខាងលើ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការប្រព័ន្ធរបស់ខ្លួនឲ្យបានត្រឹមត្រូវ ដើម្បីចៀសវាងផលប៉ះពាល់ទៅវិញទៅមកនៃប្រព័ន្ធរបស់អគ្គិសនីកម្ពុជា និងប្រព័ន្ធផលិតកម្មផ្ទាល់ខ្លួន។

**Article 1**

There is hereby granted the **Consolidated License** to **Vattanac Properties LTD** (herein after referred to as "**Licensee**") located at #43E, Steet 286, Sangkat Olympich, Khan Chamkamorn, Phnom Penh, registered in the Kingdom of Cambodia under No. Inv. 1013/05P dated December 05, 2005 pursuant to the Commercial Civil Law and Criminal law, that has applied for license to provide electric power services in authorized distribution area is determined in schedule 1, for giving the rights to the licensee as follows:

(a) To generate electricity at Phum Bratehlang, Sangkat Bratehlang, Khan Dangkor, Phnon Penh, for the purpose of supply electric power to licensee distribution systems by generating facilities defined in schedule 2, during the period specified in Article 3 of Part 1 below, subject to the conditions set out in Part 2 of this License.

(b) To distribute and supply electricity to consumers in the Authorized Distribution Areas defined in Schedule 1, Part 2 of this License, during the period specified in Article 3 of Part 1 below, subject to the Conditions set out in Part 2 of this License, by purchasing electricity from Electricite du Cambodge under the power purchase agreement (PPA) between Electricite du Cambodge and Vattanac Properties, LTD, which was signed on July 06, 2011 and/or generating electricity by its own generation facilities stated in (a) above. The licensee shall operate its system such that the operation of EDC's system and own generation are not affected adversely.

**ប្រការ២**

ល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណនេះអាចកែសម្រួល ឬ ធ្វើវិសោធនកម្មបានអនុលោមតាមបញ្ញត្តិរបស់អាជ្ញាប័ណ្ណនេះ ឬ តាមមាត្រា៧ និង ៤៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណដែលផ្តល់ឱ្យនេះអាចដកហូតបានស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ក្នុងឧបសម្ព័ន្ធទី៣ ផ្នែកទី២ របស់អាជ្ញាប័ណ្ណ ។

**Article 2**

The Conditions referred to above license are subject to modification or amendment in accordance with their terms or with Article 7 and 44 of the Electricity Law of the Kingdom of Cambodia. This license hereby granted is further subject to the terms as to revocation specified in Schedule 3 of Part 2 of this License.

**ប្រការ៣**

អាជ្ញាប័ណ្ណនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងមានអាណត្តិចំនួន ១៥(ដប់ប្រាំ)ឆ្នាំ និងអាចសុំបន្តទៀតឬស្នើសុំកែសម្រួលបានលើកលែងតែត្រូវបានដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ។

**Article 3**

This license shall come into force from the date it is signed, unless revoked earlier in accordance with the conditions of license, the term of license shall be 15 (Fifteen) years and may be renewed for further periods and with such modification as required on the application of license.

ភ្នំពេញ,ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១

Phnom Penh, October 26, 2011

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ផ្នែកទី២
# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ

## PART 2
## CONDITIONS OF LICENSE

# តារាងមាតិកា
TABLE OF CONTENTS


| | |
|---|---|
| **១ និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ** | **1 Definitions of Terms used in the License** |
| **២ ភាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **2 General Obligation of Licensee** |
| លក្ខខ័ណ្ឌទី១ ៖ កាតព្វកិច្ចគោរពច្បាប់ និងអនុក្រឹត្យ | Condition 1: Obligation on compliance with Laws and Sub-decrees |
| លក្ខខ័ណ្ឌទី២ ៖ កាតព្វកិច្ចគោរពតាមស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន | Condition 2: Obligation on compliance with Technical Standard, Safety and Environment |
| លក្ខខ័ណ្ឌទី៣ ៖ កាតព្វកិច្ចគោរពតាមបទបញ្ជា ឬសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការដាក់វិធាន និងបទប្បញ្ញត្តិ នានា សម្រាប់ការធ្វើសេវាកម្មផលិត និងចែកចាយ | Condition 3: Obligation on compliance with Orders or Decision of EAC in issuing Rules and Regulations for Generation and Distribution Services |
| លក្ខខ័ណ្ឌទី៤ ៖ កាតព្វកិច្ចគោរពតាមលក្ខខ័ណ្ឌសេវាកម្ម ដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន | Condition 4: Obligation on compliance with Conditions of Electric Power Service specified in its License |
| លក្ខខ័ណ្ឌទី៥ ៖ កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ សកម្មភាពសេវាកម្មរបស់ខ្លួនតាមការកំណត់របស់ អាជ្ញាធរ អគ្គិសនីកម្ពុជា | Condition 5: Obligation on Financial Statement and its Electric Power Service Report in accordance with EAC's Adoption |
| លក្ខខ័ណ្ឌទី៦ ៖ កាតព្វកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ | Condition 6: Obligation on Payment of License Fee |
| **៣ លក្ខខ័ណ្ឌសេវាកម្ម** | **3 Service Conditions** |
| **៣-១ លក្ខខ័ណ្ឌទូទៅ** | **3.1 General Conditions** |
| លក្ខខ័ណ្ឌទី៧ ៖ ការទំនាក់ទំនង | Condition 7: Communication |
| លក្ខខ័ណ្ឌទី៨ ៖ លក្ខខ័ណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ | Condition 8: Conditions on the Public Interest |
| លក្ខខ័ណ្ឌទី៩ ៖ លក្ខខ័ណ្ឌចំពោះការធ្វើអាជីវកម្ម | Condition 9: Conditions on the Business |
| លក្ខខ័ណ្ឌទី១០ ៖ លក្ខខ័ណ្ឌលក់មធ្យោបាយធ្វើសេវាកម្ម ក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា | Condition 10: Sale Condition of Service Facilities in the case it is required from EAC |
| **៣-២ លក្ខខ័ណ្ឌសេវាកម្មផលិតកម្ម** | **3.2 Conditions on Generation Service** |
| លក្ខខ័ណ្ឌទី១១ ៖ លក្ខខ័ណ្ឌចំពោះមធ្យោបាយផលិតកម្ម | Condition 11: Conditions on the Generation Facilities |
| លក្ខខ័ណ្ឌទី១២ ៖ លក្ខខ័ណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធផលិតកម្ម | Condition 12: Conditions on the Generation Operation |
| លក្ខខ័ណ្ឌទី១៣ ៖ លក្ខខ័ណ្ឌចំពោះការទិញអគ្គិសនីដែលមាន លក្ខណៈសេដ្ឋកិច្ច | Condition 13: Conditions on economic procurements of electricity |
| **៣-៣ លក្ខខ័ណ្ឌសេវាកម្មចែកចាយ** | **3.3 Conditions on Distribution Service** |
| លក្ខខ័ណ្ឌទី១៤ ៖ លក្ខខ័ណ្ឌចំពោះតំបន់ធ្វើសេវាកម្ម | Condition 14: Condition on Electric Power Service Area |
| លក្ខខ័ណ្ឌទី១៥ ៖ លក្ខខ័ណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម | Condition 15: Condition on Electric Power Service Utilities |
| លក្ខខ័ណ្ឌទី១៦ ៖ លក្ខខ័ណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ | Condition 16: Condition on Distribution System Operation |
| លក្ខខ័ណ្ឌទី១៧ ៖ លក្ខខ័ណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន | Condition 17: Condition on Electric Power Supply to Customers |
| **ឧបសម្ព័ន្ធទី១** ៖ តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី | **SCHEDULE 1:** Authorized Distributing Area |
| **ឧបសម្ព័ន្ធទី២** ៖ មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ | **SCHEDULE 2:** Existing Generating Facilities of the Licensee |
| **ឧបសម្ព័ន្ធទី៣** ៖ លក្ខខ័ណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ | **SCHEDULE 3:** Term of Revocation |
| **ឧបសម្ព័ន្ធទី៤** ៖ ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ | **SCHEDULE 4:** Ownership of Licensee |

# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ
# CONDITIONS OF LICENSE

| | |
|---|---|
| **១ និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ** | **1 DEFINITIONS OF TERMS USED IN THE LICENSE** |
| ពាក្យពេចន៍ទាំងឡាយណាដែលបានប្រើប្រាស់ក្នុងឯកសារអាជ្ញាប័ណ្ណនេះ ឬផ្នែកណាមួយរបស់ឯកសារនេះ និងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ត្រូវមានន័យដូចខាង ក្រោម ៖ | In this or any of the following Parts of this document and in the Schedules below, unless otherwise specified or the context otherwise requires: |
| **"សវនកម្ម"** មានន័យថា ការជំរះបញ្ជីលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងឆ្នាំការិយបរិច្ឆេទដោយសវនករមួយ ។ | "Audit" means audit on the Licensee's Financial Statement of a financial year by an auditor. |
| **"លក្ខខណ្ឌ"** មានន័យថា លក្ខខណ្ឌដែលចែងក្នុងអាជ្ញាប័ណ្ណនេះ ។ | "Condition" means a Condition set out in this License. |
| **"អ្នកប្រើប្រាស់"** មានន័យថា បុគ្គលណាមួយ ឬអ្នកទទួលសិទ្ធិបន្ត ដែលទិញឬទទួលអគ្គិសនីដើម្បីប្រើប្រាស់ និងមិនមែនដើម្បីផ្តល់ ឬលក់បន្តឱ្យអ្នកដទៃទៀតឡើយ ។ | "Consumer" means a person or his authorized representative that purchases or receives electricity for consumption and not for delivery or resale to others. |
| **"អ្នកប្រើប្រាស់ធុនតូច"** គឺអ្នកប្រើប្រាស់ ដែលទទួលការផ្គត់ផ្គង់ពីខ្សែបណ្តាញសាធារណៈតង់ស្យុងទាប ២៣០វ៉ុល ១ហ្វា និងត្រូវការកម្លាំងរហូតដល់ ៦០អំពែរ ឬ ៤០០វ៉ុល ៣ហ្វា និងត្រូវការកម្លាំងរហូតដល់ ៩០អំពែរ ។ | "Small Consumers" mean a consumer requiring power up to 60 amperes at single phase 230 volts or up to 90 amperes at three phase 400 volts is categorized as Small Consumer. Small Consumers will be supplied power from the public LV network. |
| **"អ្នកប្រើប្រាស់ធុនមធ្យម"** គឺអ្នកប្រើប្រាស់ ដែលទទួលការផ្គត់ផ្គង់ពីបន្ទប់ ភ្លើង MV/LV តាមទ្វារចរន្តតង់ស្យុងទាប ដាច់ដោយឡែក ៤០០វ៉ុល ៣ហ្វា និងមានកម្លាំងលើសពី៩០អំពែរ រហូតដល់តិចជាង ១៥០អំពែរ។ នាឡិកាស្ទង់ត្រូវតម្លើងនៅលើទ្វារចរន្តនៅក្នុងបន្ទប់ភ្លើងនោះ។ | "Medium Consumers" mean a consumer requiring power more than 90 amperes and less than 150 amperes at three phase 400 volts is categorized as Medium Consumer. Medium Consumers will be supplied power through a separate LV feeder from the MV/LV substation. The meter will be installed at the substation on this feeder. |
| **"អ្នកប្រើប្រាស់ធុនធំ"** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ជាទូទៅពីបន្ទប់ភ្លើង MV/LV ដាច់ដោយឡែកនៅក្នុងទីតាំងរបស់អ្នកប្រើប្រាស់តាមតង់ស្យុង ៤០០វ៉ុល ៣ហ្វារ និងត្រូវការកម្លាំងលើសពី១៥០អំពែ រហូតដល់តិចជាង ៤០០អំពែរ ។ ក្នុងករណីខ្លះបើអ្នកផ្គត់ផ្គង់ពិនិត្យឃើញថា អាចអនុវត្តបានសម្រាប់អ្នកប្រើប្រាស់ ដែលប្រើប្រាស់អនុភាពមួយផ្នែកនៃបន្ទប់ភ្លើងការផ្គត់ផ្គង់អាចបន្តចេញតាមខ្សែតង់ស្យុង ទាបដាច់ដោយឡែកពីបន្ទប់ភ្លើងសាធារណៈ។ នាឡិកាស្ទង់ត្រូវតម្លើងនៅលើទ្វារចរន្ត នៅបន្ទប់ភ្លើងនោះ ។ | "Big Consumers" mean a consumer requiring power more than 150 amperes and less than 400 amperes at three phase 400 volts is categorized as Big Consumer. Big Consumers will be supplied power generally from a separate MV/LV substation on their premises. The meter will be installed indoors or close to the substation. In some cases, if found feasible by the licensee, the supply to Big Consumers can be given by partly utilizing the capacity of a public MV/LV substation through a separate LV feeder. The meter will be installed at the substation on this feeder. |
| **"អ្នកប្រើប្រាស់តង់ស្យុងមធ្យម"** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតង់-ស្យុងមធ្យមពីបណ្តាញតង់ស្យុងមធ្យម និងមានតម្រូវការអនុភាពមិនតិចជាង 275kVA។ | "MV Consumers" mean a consumer requiring power more than 275kVA will be supplied power at MV by a direct connection from the MV network. MV metering |

| | | | |
|---|---|---|---|
| | នាឡិកាស្ទង់តង់ស្យុងមធ្យម ត្រូវតម្លើងនៅលើបណ្តាញតង់ស្យុង មធ្យមផ្ទាល់។ | | will be providing on the MV connection. |
| **“អ្នកប្រើប្រាស់ធុំ”** | គឺអ្នកប្រើប្រាស់ទាំងឡាយណា ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងខ្ពស់ (លើសពី ៣៥ ០០០ វ៉ុល)។ | “Bulk Consumers” | are consumers supplied power at high voltage (above 35 000 Volts). |
| **“អតិថិជន”** | មានន័យថា បុគ្គលណាមួយដែលបានទទួលការផ្គត់ផ្គង់ ឬទាមទារឱ្យមានការផ្គត់ផ្គង់អគ្គិសនីឱ្យទីតាំងខ្លួនក្នុងតំបន់អនុញ្ញាត ។ | “Customer” | means any person supplied or requiring to be supplied with electricity at premises within the authorized area. |
| **“អាជីវកម្មចែកចាយ”** | មានន័យថា ការធ្វើអាជីវកម្មរបស់អ្នកកាន់ អាជ្ញាប័ណ្ណចែកចាយ ឬមានលក្ខណៈជា ៖<br>(ក) ការចែកចាយអគ្គិសនី តាមរយៈប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ គិតរួមទាំងអាជីវកម្មក្នុងការផ្គត់ផ្គង់ ការតភ្ជាប់ប្រព័ន្ធជាមួយប្រព័ន្ធនេះ<br>(ខ) ការផ្តល់សេវាសម្រាប់នាឡិកាស្ទង់ និង<br>(គ) ការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។ | “Distribution Business” | means the business of the Distribution Licensee or ancillary to:<br>(a) the distribution of electricity through the Licensee’s Distribution System, including any business in providing connections to such system;<br>(b) provision of Metering Services; and<br>(c) Supply of electricity to consumers. |
| **“អាជ្ញាប័ណ្ណចែកចាយ”** | មានន័យថា អាជ្ញាប័ណ្ណចែកចាយដែលបានផ្តល់ ក្នុងប្រការ១(ខ) នៃផ្នែកទី១ ។ | “Distribution License” | means the Distribution License granted in Article 1(b) of Part 1. |
| **“ប្រព័ន្ធចែកចាយ”** | មានន័យថា ខ្សែបណ្តាញអគ្គិសនីទាំងអស់របស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងតំបន់ចែកចាយដែលបានអនុញ្ញាត និងខ្សែបណ្តាញអគ្គិសនីណាមួយផ្សេងទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថាជាផ្នែកនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ព្រមទាំងនាឡិកាស្ទង់ និងបរិក្ខាអគ្គិសនីណាមួយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដែលបានប្រើប្រាស់សម្រាប់ចែកចាយអគ្គិសនីដោយអ្នកកាន់អាជ្ញាប័ណ្ណដោយឡែកចំពោះអ្នកចែកចាយដទៃណាមួយផ្សេងទៀត វាមានអត្ថន័យដូចគ្នា ដូចមានចែងក្នុងអាជ្ញាប័ណ្ណដែលបានកាន់ដោយ អ្នកកាន់អាជ្ញាប័ណ្ណចែកចាយនោះ ។ | “Distribution System” | Means all electric network of the Licensee within the Licensee’s authorized distribution area and any other electric lines which EAC may specify as forming part of the Licensee’s Distribution System, and includes any electrical plant and meters of the Licensee which are used in connection with the distribution of electricity by the Licensee; and, in relation to any other distributor, it shall have the same meaning as it has in the license held by such distributor. |
| **“អ្នកចែកចាយ”** | មានន័យថា បុគ្គលណាមួយដែលបានកាន់អាជ្ញាប័ណ្ណចែកចាយ ។ | “Distributor” | means any person who holds a Distribution License. |
| **“អាជ្ញាធរអគ្គិសនីកម្ពុជា”** | មានន័យថា អាជ្ញាធរអគ្គិសនីកម្ពុជា ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ | “EAC” | means the Electricity Authority of Cambodia established by the Electricity Law promulgated by Royal Decree No. NS/RKM/ 0201/03 dated February 2, 2001. |
| **“អាជីវកម្មផលិតកម្ម”** | មានន័យថា ការធ្វើអាជីវកម្ម (ប្រសិនបើមាន) របស់អ្នកកាន់អាជ្ញាប័ណ្ណ (អ្នកកាន់អាជ្ញាប័ណ្ណផលិត) ក្នុងការផលិតថាមពលអគ្គិសនី ។ | “Generation Business” | means the business (if any) of the Licensee (as holder of the Generation License) in the generation of electricity. |
| **“អាជ្ញាប័ណ្ណផលិតកម្ម”** | មានន័យថា អាជ្ញាប័ណ្ណផលិតកម្ម ដែលបានផ្តល់ឱ្យក្នុងប្រការ ១(ក) នៃផ្នែកទី១ ។ | “Generation License” | means the Generation License granted in Article 1 (a) of Part 1. |
| **“ឯកសារអាជ្ញាប័ណ្ណ”** | មានន័យថា ឯកសារនេះដែលមានពីផ្នែកទី១ ដល់ផ្នែកទី២ និងឧបសម្ព័ន្ធទី១ ដល់ ឧបសម្ព័ន្ធទី៣ ។ | “License Document” | means this document comprising Part 1 to 2 and Schedules 1 to 3. |

| | |
|---|---|
| "អ្នកកាន់អាជ្ញាប័ណ្ណ" | មានន័យថា ក្រុមហ៊ុន **វឌ្ឍនៈ ប្របភើធី អិលធីឌី** |
| "បរិក្ខានាឡិកាស្ទង់" | រួមមាន នាឡិកាស្ទង់ និងបរិក្ខាពាក់ព័ន្ធដទៃទៀត ដែលមានឥទ្ធិពលផ្ទាល់ លើការដំណើរការនាឡិកាស្ទង់នោះ ។ |
| "ការជូនដំណឹង" | មានន័យថា (ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀត) គឺការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬដោយមធ្យោបាយសមស្របណាមួយផ្សេងទៀត ។ |
| "ការបញ្ជាក់" | រួមមានការបដិសេធ ឬការសំណូមពរណាមួយ ដែលបានធ្វើជាលាយលក្ខណ៍អក្សរ ។ |

## ២ ភាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ

**លក្ខខ័ណ្ឌទី១ ៖ ភាតព្វកិច្ចគោរពច្បាប់ និង អនុក្រឹត្យ**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមកាតព្វកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម /១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងអនុក្រឹត្យនានា ពាក់ព័ន្ធនឹងការការពារបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។

**លក្ខខ័ណ្ឌទី២ ៖ ភាតព្វកិច្ចគោរពតាមស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន**

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមស្តង់ដាទាក់ទងទៅនឹងកិច្ចប្រតិបត្តិការបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន ដែលបង្កើតឡើង និងផ្សព្វផ្សាយដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**លក្ខខ័ណ្ឌទី៣ ៖ ភាតព្វកិច្ចគោរពតាមបទបញ្ជា ឬសេចក្តីសម្រេចរបស់ អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការដាក់វិធាន និងបទប្បញ្ញត្តិ នានាសម្រាប់ការធ្វើសេវាកម្មផលិត និងចែកចាយ**

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងនីតិវិធីនានា ដែលអាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចដាក់ឱ្យអនុវត្ត សម្រាប់ការធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនី ។

២- ក្នុងករណីជាក់លាក់ណាមួយអាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ) អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ តាមវាក្យខ័ណ្ឌទី១ ចំពោះផ្នែកណាមួយនៃវិធានបទប្បញ្ញត្តិនីតិវិធី និងតាមទំហំណាមួយដែលកំណត់ក្នុងលិខិតណែនាំ ។

**លក្ខខ័ណ្ឌទី៤ ៖ ភាតព្វកិច្ចគោរពតាមលក្ខខ័ណ្ឌសេវាកម្ម ដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមលក្ខខ័ណ្ឌសេវាកម្ម ដែលកំណត់ក្នុងអាជ្ញាប័ណ្ណនេះ ។

| | |
|---|---|
| "Licensee" | means **Vattanac Properties LTD** |
| "Metering Equipment" | includes any meter and associated equipment, which materially affects the operation of that meter. |
| "Notice" | means (unless otherwise specified) notice given in writing or by any other reasonable means. |
| "Representation" | includes any objection or any other proposal made in writing. |

## 2 GENERAL OBLIGATION OF LICENSEE

**Condition 1: Obligation on compliance with Laws and Sub-decrees.**

1. The Licensee shall comply with the Electricity Law of the Kingdom of Cambodia, other Laws and Sub Decrees relating to the Laws.
2. The Licensee is subjected to the environmental obligations as specified in the Law on Environmental Protection promulgated by the Royal Decree NS/RKM/1296/36, dated 24/12/1996 and Other Sub-Decrees on Environmental Protection of the Kingdom of Cambodia.

**Condition 2: Obligation on compliance with Technical Standard, Safety and Environment**

1. The Licensee shall comply with the standard relating to technical operation, safety and environment, used and published by Ministry of Industry, Mines and Energy.

**Condition 3: Obligation on compliance with EAC's Orders, Decisions, Rules and Regulations for Generation and Distribution Services**

1. The Licensee shall comply with the provisions of the Rules, Regulations and Procedures on the electric power generation and distribution services issued by EAC.
2. In specific case, EAC may (following consultation with the Licensee) issue directions relieving the Licensee of its obligations under paragraph 1 in respect of such parts of the Rules, Regulations, and Procedures for such periods specified in those directions.

**Condition 4: Obligation on compliance with Conditions of Electric Power Service specified in its License**

1. The Licensee shall comply with the provisions of service condition in this license.

**លក្ខខណ្ឌទី៥ ៖ ភាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ សកម្មភាពសេវាកម្មរបស់ខ្លួន តាមការកំណត់របស់ អាជ្ញាធរអគ្គិសនីកម្ពុជា**

១- ឆ្នាំការិយបរិច្ឆេទនៃអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវចាប់គិតពីថ្ងៃទី ១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវច្បាប់ចំលងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចមិនលើសពី៣ខែក្រោយពី បញ្ចប់ឆ្នាំការិយបរិច្ឆេទដែលរបាយការណ៍នោះពាក់ព័ន្ធ ។ ការធ្វើសវនកម្មអាចជំនួសដោយការត្រួតពិនិត្យរបស់អាជ្ញាធរក្នុងករណី ដែលសភាពការណ៍ជាក់ស្តែងតម្រូវ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវបណ្តា ព័ត៌មានទាំងឡាយដែលអាជ្ញាធរទាមទារជាបន្តបន្ទាប់តាមបែបបទ និងទម្រង់កំណត់ដោយអាជ្ញាធរ ដើម្បីអាចឱ្យអាជ្ញាធរផ្ទៀងផ្ទាត់មើលការអនុវត្តន៍របស់អ្នកកាន់អាជ្ញាប័ណ្ណតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណនេះ និងតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសម្រេចផ្សេងៗទៀត ។

៤- ដោយមិនគិតពីភាពទូទៅនៃវាក្យខណ្ឌទី៣ អាជ្ញាធរអគ្គិសនីកម្ពុជាអាចទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់នូវព័ត៌មានណាមួយឱ្យមានលក្ខណៈលម្អិតខ្លាំងជាង ឬខុសពីការផ្តល់ព័ត៌មានធម្មតាដល់អាជ្ញាធរអគ្គិសនី កម្ពុជា ។

**លក្ខខណ្ឌទី៦ ៖ ភាតព្វកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ**

១- ចាប់ពីថ្ងៃចូលជាធរមានរហូតដល់ថ្ងៃបញ្ចប់អាណត្តិនៃអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ **"កម្រៃអាជ្ញាប័ណ្ណប្រចាំខែ"** តាមអាត្រាកម្រៃអាជ្ញាប័ណ្ណ និងរូបមន្តគណនាកម្រៃអាជ្ញាប័ណ្ណ ដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់ឆ្នាំ ការិយបរិច្ឆេទនីមួយៗ ដោយអនុលោមតាមមាត្រា ២៧ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣ នៃអនុក្រឹត្យស្តីពីការកំណត់កំរិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណសម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- វិក្កយបត្រនៃកម្រៃអាជ្ញាប័ណ្ណប្រចាំខែ ត្រូវចាត់ទុកថាជំពាក់ និងត្រូវបង់ក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអ្នកកាន់អាជ្ញាប័ណ្ណបានទទួលវិក្កយបត្រ ។

## ៣ លក្ខខណ្ឌសេវាកម្ម

### ៣-១ លក្ខខណ្ឌទូទៅ

**លក្ខខណ្ឌទី៧ ៖ ការទំនាក់ទំនង**

១- រាល់ទំនាក់ទំនងទាំងអស់ពាក់ព័ន្ធជាមួយអាជ្ញាប័ណ្ណនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយយកភាសាខ្មែរជាគោល ។

**លក្ខខណ្ឌទី៨ ៖ លក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ**

១- អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវបោះបង់ចោលឬដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយមុនពេលមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរនូវសំណើជាលាយលក្ខណ៍អក្សរស្តីពីគោលបំណងរបស់គេក្នុងការបោះបង់ចោល ឬបដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ ដោយភ្ជាប់ជាមួយព័ត៌មានបន្ថែមផ្សេងៗទៀតតាម ដែលអាជ្ញាធរស្នើសុំពាក់ព័ន្ធជា

**Condition 5: Obligation on Financial Statement and its Electric Power Service Report in accordance with EAC's Adoption**

1. The financial year of the Licensee shall be reckoned every year from 1st January to the following 31st December.

2. The Licensee shall submit to EAC the copy of its audited financial statement not later than 3 months after the end of financial year to which they relate. The audit can be replaced by the control of EAC in the case that actual situation requires.

3. The Licensee shall provide, in the manner and form determined by EAC, such information as EAC may require from time to time monitoring the Licensee's compliance with the conditions of this license, provision of the electricity law and any other legislative or regulatory requirements.

4. Without prejudice to the generality of paragraph 3, EAC may require the Licensee to supply information which is more extensive than or differs from that required to be prepared and supplied to EAC.

**Condition 6: Obligation on Payment of License Fee**

1. From the effective date to the end of the term of license, the Licensee shall pay to EAC "The Monthly License Fee" which is calculated according to the rate of license fee and the formula determined by EAC for each financial years pursuant to Article 27 of the Electricity Law of the Kingdom of Cambodia and Article 3 of Sub-Decree defining the maximum of License fee to be implemented to the electric power services in the Kingdom of Cambodia.

2. Each invoice of monthly license fee shall be due and payable within 14 days after the day on which Licensee receives it.

## 3 SERVICE CONDITIONS

### 3.1 GENERAL CONDITIONS

**Condition 7: Communication**

1. All communications relating to this License shall be written in Khmer as an official.

**Condition 8: Conditions on the Public Interest**

1. The Licensee shall not dispose or relinquish operational control over any relevant asset prior the consent from EAC.

2. The Licensee shall give to EAC written proposal of its intention to dispose of or relinquish operational control over any relevant asset, together with such further information as EAC may request relating

មួយនឹងអចលនទ្រព្យនោះ ឬកាលៈទេសៈនៃការលះបង់ ឬ បដិសេធចោលការគ្រប់គ្រងនេះ ឬគោលបំណងនៃបុគ្គលណាមួយ ដែលចង់ទទួលយកឬទទួលគ្រប់គ្រងដំណើរការលើអចលនទ្រព្យនោះ។

៣- អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ) អាចយល់ព្រមឬមិនយល់ព្រមនូវសំណើនេះ ។

៤- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពិគ្រោះយោបល់ជាមួយតំណាងបុគ្គលិកកម្មកររបស់ខ្លួន ដើម្បីបង្កើតឱ្យមានយន្តការឬវេទិកាជាប្រចាំមួយសម្រាប់រួមគ្នាគិតគូរពីបញ្ហារួមពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាព របស់ពួកគេ ។

៥- នៅពេលមានការកំណត់ពីអាជ្ញាធរអគ្គិសនីកម្ពុជា ឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងមួយថ្ងៃ ២៤ម៉ោង នោះអ្នកកាន់ អាជ្ញាប័ណ្ណត្រូវបំពេញតាមសំណូមពរនោះ ។

**ល័ក្ខខ័ណ្ឌទី៩ ៖ ល័ក្ខខ័ណ្ឌចំពោះការធ្វើអាជីវកម្ម**

១- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវប្រើប្រាស់អចលនទ្រព្យ នៃអាជីវកម្មរបស់អាជ្ញាប័ណ្ណនេះសម្រាប់គោលបំណងអ្វីក្រៅពីការផលិត និងការចែកចាយដូចដែលបានកំណត់ក្នុងឯកសារនេះ ដោយគ្មានការអនុញ្ញាតជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

២- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវទទួលយក ឬចូលរួមជាមួយអាជីវកម្មអគ្គិសនីដទៃណាមួយទៀត ដែលមិនបញ្ជាក់ក្នុងអាជ្ញាប័ណ្ណរួមទាំង អាជីវកម្មផលិតកម្ម បញ្ជូន ចែកចាយ ឬលក់ថាមពលឡើយ ដោយគ្មានការអនុញ្ញាតជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៣- នៅគ្រប់ពេល អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវប្រគល់អាជ្ញាប័ណ្ណ ឬផ្ទេរការកាន់កាប់របស់ខ្លួន ឬផ្នែកណាមួយនៃអាជ្ញាប័ណ្ណដោយលក់ បញ្ចាំ ជួល ប្តូរឬផ្សេងពីនេះដោយគ្មានការអនុញ្ញាតពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ។

៤- កិច្ចព្រមព្រៀងណាមួយពាក់ព័ន្ធជាមួយកិច្ចការ ដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី១, ទី២ និងទី៣ ខាងលើបើពុំមានការឯកភាពជាលាយល័ក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាទេ ត្រូវចាត់ទុកជាមោឃៈ និងត្រូវចាត់ទុកជាការរំលោភលើល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ។

៥- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការ និងគ្រប់គ្រងសេវាកម្មអគ្គិសនី ដែលបានផ្តល់ដោយអាជ្ញាប័ណ្ណនេះឱ្យមានប្រសិទ្ធភាព គុណភាព និងតម្លាភាព ដោយអនុលោមតាមល័ក្ខខ័ណ្ឌកំណត់ក្នុងអាជ្ញាប័ណ្ណនេះ និងបទប្បញ្ញត្តិដែលកំណត់ក្នុងវិធាននានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

៦- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពង្រីក និងកែលម្អមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួនតាមកម្មវិធីដែលបានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជាដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីដល់គ្រប់អ្នកប្រើប្រាស់ក្នុងតំបន់ ។

៧- អ្នកកាន់អាជ្ញាប័ណ្ណត្រូវលក់អគ្គិសនី តាមបញ្ជីថ្លៃលក់អគ្គិសនី ដែលអនុម័ត ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

៨- អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឱ្យអ្នកកាន់អាជ្ញប័ណ្ណកសាងថ្លៃដើមអគ្គិសនី ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីអាជ្ញាធរអគ្គិសនីកម្ពុជាពិនិត្យនិងអនុម័តលើបញ្ជីថ្លៃលក់អគ្គិសនីថ្មី ប្រសិនបើអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថា ត្រូវធ្វើការកែសម្រួលថ្លៃលក់អគ្គិសនី ។

**ល័ក្ខខ័ណ្ឌទី១០ ៖ ល័ក្ខខ័ណ្ឌលក់មធ្យោបាយធ្វើសេវាកម្ម ក្នុងករណី**

to such asset or the circumstances of such intended disposal or relinquishment of control or to the intentions in regard thereto of the person proposing to acquire such asset or operational control over such asset.

3. EAC may (following consultation with the Licensee) consents or not consents to this proposal.

4. The Licensee shall consult with appropriate representatives of persons employed by it in order to establish and maintain an appropriate machinery or forum for the joint consideration of matters of mutual concern in respect of the health and safety of such persons.

5. When the EAC obligates the licensee to supply electricity in 24 hours per day, licensee shall meet that obligation.

**Condition 9: Conditions on the Business**

1. The Licensee shall not use the relevant assets of this License's business for the purpose other than Generation and Distribution as specified in this document without prior approval of EAC.

2. The Licensee shall not acquire or associate himself with any additional business, which is not identified in the license, including the business of generating, transmitting, distributing or supply of energy without an approval from EAC.

3. The Licensee shall not, at any time, assign his License or transfer his undertaking, or any part thereof, by sale, mortgage, lease, exchange or otherwise, unless approved by EAC.

4. Any agreement relating to any transaction of the nature described above at paragraph 1, 2 and 3 unless made with the prior written consent of EAC, shall be void and will constitute violation of Conditions of License.

5. The Licensee shall operate and manage the Services provided by this License in an efficient, quality and transparent manner in accordance with the requirement of this License and the regulations defined in the Rules issued by EAC.

6. The Licensee shall extend and improve its facilities in accordance with its plan approved by EAC to ensure the electricity supply to all consumers in the area.

7. The licensee shall sell electricity at the tariff schedules approved by EAC.

8. Licensee shall summit the cost of electricity to EAC for approval on new tariff schedules in the case EAC requires to change it.

**មានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា**

១- ក្នុងរយៈពេល៦ខែ បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណនេះអ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាអនុម័តនិងចុះបញ្ជីអចលនទ្រព្យសំរាប់ធ្វើសេវាកម្មរបស់ខ្លួន ។ បញ្ជីនេះត្រូវបញ្ជាក់លម្អិតនៅឆ្នាំចាប់ផ្តើមដំណើរការអាជីវកម្ម និងតម្លៃដើមនៃមធ្យោបាយធ្វើសេវាកម្ម នីមួយៗ។ បន្ទាប់ពីនោះសម្រាប់ឆ្នាំនីមួយៗនៅមុនថ្ងៃទី១៥ ខែកុម្ភៈ អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាកែសម្រួលបញ្ជីមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួនដែលមានជាក់ស្តែង ដល់ថ្ងៃទី៣១ ខែធ្នូ កន្លងមក ។ បញ្ជីនេះត្រូវបង្ហាញនូវមធ្យោបាយធ្វើសេវាកម្មដែលមានពីដើមឆ្នាំ ដែលបានបន្ថែមឬលុបចេញក្នុងឆ្នាំដោយមានបញ្ជាក់តម្លៃ មធ្យោបាយធ្វើសេវាកម្មនោះ និងមធ្យោបាយធ្វើសេវាកម្មដែលមាននៅចុងឆ្នាំ ។

២- ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនានាក្នុងករណីដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណលក់ ឬផ្ទេរមធ្យោបាយធ្វើសេវាកម្ម ដែលបានចុះបញ្ជីនៅអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យអ្នកបន្តវេនមួយផ្សេងទៀតតាមគោលការណ៍ហិរញ្ញវត្ថុ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

**៣-២ លក្ខខណ្ឌសេវាកម្មផលិតកម្ម**

**លក្ខខណ្ឌទី១១ ៖ លក្ខខណ្ឌចំពោះមធ្យោបាយផលិតកម្ម**

១- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងបន្ថែមមធ្យោបាយផលិតកម្មថ្មីថែមទៀត ពេលនោះត្រូវស្នើសុំការអនុញ្ញាតពីអាជ្ញាធរអគ្គិសនី ចំពោះមធ្យោបាយផលិតកម្មថ្មីនីមួយៗ ។

២- មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី២ ។

៣- ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណ បានទទួលសិទ្ធិធ្វើសេវាកម្មលើមធ្យោបាយផលិតកម្មបន្ថែមទៀតតាមខ្លឹមសារប្រការ១ នៃផ្នែកទី១ របស់អាជ្ញាប័ណ្ណឧបសម្ព័ន្ធទី២នៃអាជ្ញាប័ណ្ណត្រូវធ្វើការកែសំរួលជាថ្មី

**លក្ខខណ្ឌទី១២ ៖ លក្ខខណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធផលិតកម្ម**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើផែនការ និងអភិវឌ្ឍផ្នែកនីមួយៗ នៃប្រព័ន្ធផលិតកម្មរបស់ខ្លួន ដើម្បីឱ្យកិច្ចដំណើរការផលិតកម្មមានប្រសិទ្ធ ភាព ស្ថេរភាព និងគុណភាព ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំ និងជូនព័ត៌មានឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យបានដឹងនូវផែនការសកម្មភាព ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តដើម្បីឱ្យកិច្ចដំណើរការផលិតកម្មមានប្រសិទ្ធភាព ស្ថេរភាព និងគុណភាព ។

**លក្ខខណ្ឌទី១៣ ៖ លក្ខខណ្ឌចំពោះការទិញអគ្គិសនីដែលមានលក្ខណៈ សេដ្ឋកិច្ច**

១- ប្រសិនបើនៅពេលខាងមុខមានប្រភពអគ្គិសនីផ្សេង ដែលមានតម្លៃថោកជាង និងមានស្ថេរភាពជាងការផលិតផ្ទាល់របស់អ្នកកាន់អាជ្ញាប័ណ្ណអាជ្ញាធរអគ្គិសនីកម្ពុជា អាចតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណទិញអគ្គិសនី ដែលមានតម្លៃថោកនិងមានស្ថេរភាពនោះមកផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់ ។ កិច្ចព្រមព្រៀងលក់ទិញអគ្គិសនីរវាងអ្នកកាន់អាជ្ញាប័ណ្ណនិងម្ចាស់ប្រភពអគ្គិសនីនោះត្រូវមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជាមុនពេលចុះហត្ថលេខា ។

**Condition 10: Sale Condition of Service Facilities in the case it is required from EAC**

1. Within six months after receiving this license, the licensee shall submit the list of its facilities for approval and registering at EAC as relevant asset. The list should also give details on year of commissioning and the original cost of each facility. Thereafter, for revision of the list of relevant asset, the licensee shall submit to EAC by 15th February each year, the list of its facilities as on 31st December of the previous year. The list should indicate the facilities in the beginning of the year, additions made during the year with its cost, deletion made during the year with its original cost and facilities at the end of the year.

2. Under Electricity Law and Sub-decrees, in the case of revocation of license, EAC can require licensee to sale or transfer its facilities registered with EAC to the successor in accordance with financial principle determined by EAC.

**3.2 CONDITIONS ON GENERATION SERVICE**

**Condition 11: Conditions on the Generation Facilities**

1. Under this license, if the licensee intends to add new generation facilities, then he must ask for permission from EAC for each new generation facility.

2. The existing generation facilities of the Licensee are specified in Schedule 2.

3. In case the Licensee received the right to do the business on the additional power generation facilities, Article 1 of part 1 of the license, and schedule 2 of license shall be revised accordingly.

**Condition 12: Conditions on the Generation System Operation**

1. The Licensee shall plan and develop each part of its generation system, such that the generation operation can be performed efficiently, sustain ably and qualitatively.

2. The Licensee shall draw up and inform to EAC the action plan by which the Licensee shall perform to provide the efficient, sustainable and quality generation services.

**Condition 13: Conditions on economic procurements of electricity**

1. If in future alternative source of supply, which is cheaper and more reliable than own generation, is available, then EAC may require the licensee to procure electricity at the best effective reasonable price having regard to security and reliability of electric power supply. The licensee shall submit power purchase agreement between the licensee and owner of the electricity source that it

**៣-៣ លក្ខខ័ណ្ឌសេវាកម្មចែកចាយ**

**លក្ខខ័ណ្ឌទី១៤ ៖ លក្ខខ័ណ្ឌចំពោះតំបន់ធ្វើសេវាកម្ម**

១- អាជ្ញាប័ណ្ណនេះ ផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយនៅក្នុងតំបន់អនុញ្ញាតដែលមានកំណត់ព្រំដែនច្បាស់លាស់ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១ នៃអាជ្ញាប័ណ្ណនេះ ។

២- អ្នកប្រើប្រាស់ធុនធំ និងអ្នកប្រើប្រាស់ដុំក្នុងតំបន់ចែកចាយខាងលើ អាចមានសិទ្ធិជ្រើសរើសប្រភពផ្គត់ផ្គង់ពីប្រព័ន្ធបញ្ជូន ឬពីប្រព័ន្ធចែកចាយមេផ្សេងទៀតបាន ប្រសិនបើមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

**លក្ខខ័ណ្ឌទី១៥ ៖ លក្ខខ័ណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម**

១- អ្នកកាន់អាជ្ញាប័ណ្ណ មានកាតព្វកិច្ចអភិវឌ្ឍន៍មធ្យោបាយធ្វើសេវាកម្មរបស់ខ្លួនដើម្បីអាចផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់របស់ខ្លួនបាន និងប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើផែនការ និងអភិវឌ្ឍន៍ប្រព័ន្ធចែកចាយរបស់ខ្លួនទៅតាមលក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំនិងប្រកាសឱ្យប្រើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**លក្ខខ័ណ្ឌទី១៦ ៖ លក្ខខ័ណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការការផ្គត់ផ្គង់ និងការចែកចាយរបស់ខ្លួនតាមស្តង់ដាប្រតិបត្តិដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមតាមមាត្រា៣ និង ៧(ង) របស់ច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឱ្យមានប្រភពអគ្គិសនីគ្រប់គ្រាន់មួយសម្រាប់ផ្គត់ផ្គង់ឱ្យអតិថិជនរបស់ខ្លួន ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធានានូវលក្ខខ័ណ្ឌដូចខាងក្រោម ៖

(ក) មិនត្រូវមានការកាត់ផ្តាច់លើសពីរយៈពេលស្តង់ដា ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និង

(ខ) តង់ស្យុង និងហ្វ្រេកង់អគ្គិសនីមិនត្រូវហួសពីកំរិតព្រំដែនដំណើរការជាធម្មតាដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមកូដប្រព័ន្ធចែកចាយមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជានឹងកំណត់នៅពេលក្រោយ ។

**លក្ខខ័ណ្ឌទី១៧ ៖ លក្ខខ័ណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជាស្តីពីលក្ខខ័ណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ក្នុងការចែកចាយអគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវរើសអើងរវាងបុគ្គល ឬក្រុមបុគ្គលណាមួយជាមួយបុគ្គលឬក្រុមបុគ្គលណាមួយទៀតឡើយ ។

proposes to execute to EAC for approval.

**3.3 CONDITIONS ON DISTRIBUTION SERVICE**

**Condition 14: Conditions on Electric Power Service Area**

1. This license provides the rights to licensee to distribute electric power in authorized distribution area as clearly indicated the location in schedule 1 of this license.

2. Big consumers and bulk consumers in the above distribution area may have the right to select other supply sources from the transmission line or main distribution network if they have the approval from EAC.

**Condition 15: Conditions on Electric Power Service Facilities**

1. The licensee shall have the obligation to develop its electric power service facilities in order to supply the electricity to its consumers with efficiency and security. The licensee shall plan and develop its distribution system in confirming with the General Requirement of Electric Power Technical Standards of the Kingdom of Cambodia issued by Ministry of Industry, Mines and Energy.

**Condition 16: Conditions on Distribution System Operation**

1. The Licensee shall conduct its Supply and Distribution Operation in accordance with standards of performance issue by EAC pursuant to Article 3 and 7(e) of the Electricity Law of the Kingdom of Cambodia.

2. The Licensee shall ensure availability of sufficient power sources for supply to its customers. Licensee shall ensure the following conditions:

   (a) Supply of electricity may not be discontinued for more than the time limit approved by EAC; and

   (b) The voltage and frequency of electricity may not vary beyond the permissible operational limits approved by EAC.

3. The Licensee shall comply with the Distribution Code approved by EAC.

**Condition 17: Conditions on Electric Power Supply to Customers**

1. The Licensee shall comply with the EAC's Regulations on general conditions of supply of electricity in the Kingdom of Cambodia.

2. In the provision of electricity, the Licensee shall not discriminate between persons or classes of persons.

# ឧបសម្ព័ន្ធទី១
# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

## SCHEDULE 1

## AUTHORIZED DISTRIBUTING AREA

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី ដែលអ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្តល់សេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់គឺផ្នែកខ្លះនៃសង្កាត់ក្រាំងពង្រ និងសង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ | 1. The authorized distribution area, where the licensee has the right to provide the electricity and supply service at some parts of Sangkat Krangpongro and Sangkat Bratehlang, Khan Dangkor, Phnon Penh. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះកំណត់ដោយ "ផែនទីកំណត់ព្រំប្រទល់លេខ 325LD-Vattanac Properties LTD-2011 " ដែលភ្ជាប់មកជាមួយ ។ | 2. This authorized distribution area is determined by "the boundary map No. 325LD-Vattanac Properties LTD-2011" attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀតពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១ នេះត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if the licensee intends to request the extension or the additional distribution areas then the licensee shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |

# ឧបសម្ព័ន្ធទី២
# មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ
# SCHEDULE 2
## EXISTING GENERATING FACILITIES OF THE LICENSEE

| | |
|---|---|
| **មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **Licensee's Generation Facilities** |
| **ក-រោងម៉ាស៊ីន** | **A. Generator House** |
| ១- ទីតាំងម៉ាស៊ីនភ្លើងរបស់អ្នកកាន់អាជ្ញាប័ណ្ណស្ថិតនៅភូមិប្រទះឡាង សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានី ភ្នំពេញ ។ | 1. The licensee’s generator located at Phum Bratehlang, Sangkat Bratehlang, Khan Dangkor, Phnon Penh. |
| **ខ-លក្ខណៈទូទៅនៃម៉ាស៊ីន** | **B. General Specifications of the Generators** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៤គ្រឿង ដែលមានអានុភាពតម្លើងសរុប ៣១៤០kVA ៖<br>-ម៉ាស៊ីនទី១, ទី២ និងទី៣ អានុភាព ៦៣០kVA<br>-ម៉ាស៊ីនទី៤ អានុភាព ១២៥០kVA | 1. The licensee has 04 units of generator with the total installed capacity of 3140 kVA:<br>-1st, 2nd and 3rd Generator : installed capacity kVA<br>-4th Generators : installed capacity kVA |
| ២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងដៀសែល ។ | 2. The normal fuel for the generators are Diesel Oil (DO). |
| **គ-ការស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម** | **C. Request of changing or adding generating facility** |
| ១- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្មពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្មឧបសម្ព័ន្ធទី២ នេះត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្មនោះ។ | 1. Under this license, if the licensee intends to request the changing or the additional generation facility then the licensee shall prepare all necessary documents and submit to EAC in accordance with the EAC’s determination. After EAC authorized to change or to add generation facility, this schedule 2 shall be revised and attached with that authorization. |

# ឧបសម្ព័ន្ធទី៣
# លក្ខខ័ណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ
# SCHEDULE 3

## TERM OF REVOCATION

| | |
|---|---|
| ១- អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការដកហូតអាជ្ញាប័ណ្ណ ដែលបានផ្តល់ដោយឯកសារនេះបានគ្រប់ពេលតាមកាលៈទេសៈ ដូចខាងក្រោម ៖ | 1. EAC may at any time consider revocation of license granted by this Document under following circumstance: |
| (ក) ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណសំណូមពរជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរអគ្គិសនីកម្ពុជាសុំឱ្យដកហូតអាជ្ញាប័ណ្ណនេះ ។ | (a) if the Licensee requests in writing to EAC that that such license may be revoked; |
| (ខ) ប្រសិនបើ ចំនួនទឹកប្រាក់ដែលត្រូវបង់ណាមួយតាមល័ក្ខខ័ណ្ឌទី៦ ទាក់ទងជាមួយអាជ្ញាប័ណ្ណនេះមិនបានទូទាត់ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយថ្ងៃដែលកំណត់ឱ្យបង់ ឬមិនបានទូទាត់ក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានប្រគល់លិខិតជូនដំណឹងឱ្យទៅអ្នកកាន់អាជ្ញាប័ណ្ណថា ថ្ងៃទូទាត់បានផុតកំណត់ហើយ ប៉ុន្តែលិខិតជូនដំណឹងនេះមិនត្រូវចេញមុន ដែលចំនួនទឹកប្រាក់នេះត្រូវកំណត់ឱ្យបង់ឡើយ ។ | (b) if any amount payable under Condition 6 in relation to this license is unpaid 15 days after it has become due or remains unpaid for a period of 14 days after EAC has given the Licensee notice that the payment is overdue provided that no such notice shall be given earlier than the day on which the amount payable became due; |
| (គ) ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិខុសពីល័ក្ខខ័ណ្ឌណាមួយនៃអាជ្ញាប័ណ្ណ និងមិនគោរពតាមបទបញ្ជាចុងក្រោយរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែតម្រូវកំហុសនេះ ឬ | (c) if the Licensee in the opinion of the EAC has committed a material breach of any of the terms and Conditions of such License and does not comply with a final order of EAC to rectify such breach; or |
| (ឃ) ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញភារៈកិច្ច និងកាតព្វកិច្ចដែលបានកំណត់ដោយអាជ្ញាប័ណ្ណនេះឱ្យបានពេញលេញ និងប្រកបដោយ ប្រសិទ្ធភាព ឬ | (d) if the Licensee in the opinion of the EAC, is not in a position to fully and efficiently discharge the duties and obligations imposed on Licensee by such License; or |
| (ង)ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិខុសដោយចេតនា និងគ្មានហេតុផលចំពោះបទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌដែលកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិដែលសម្រេចដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជារួមទាំងច្បាប់ស្តីពីការការពារ បរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ សុវត្ថិភាព សុខភាព ពន្ធដារ ព្រមទាំងការអនុវត្តន៍ការការពារ និងស្តង់ដានៃប្រព័ន្ធ អគ្គិសនី ។ | (e) if in the opinion of EAC the Licensee has committed a willful or unreasonable default to comply with conditions set forth in the rules and regulations adopted by EAC, and the Laws of the Kingdom of Cambodia, including Laws regarding environmental protection, natural source, safety, health, taxes, and electric system performance, protection and standards; |
| ២- នៅគ្រប់ពេលអាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលមិនតិចជាង ៣ខែ ទៅអ្នកកាន់អាជ្ញាប័ណ្ណស្តីពីមូលហេតុ ដែលឈរលើនេះអាជ្ញាប័ណ្ណណាមួយតម្រូវឱ្យដកហូត ។ | 2. EAC may at any time give not less than 3 months notice in writing to the Licensee stating the grounds on which any License is proposed to be revoked. |
| ៣- ជំនួសឱ្យការដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុញ្ញាតឱ្យអាជ្ញាប័ណ្ណនេះបន្តនៅជាធរមានបន្តទៀត បើសិនជាមានល័ក្ខខ័ណ្ឌបន្ថែមទៀតដែលយល់ថាគួរត្រូវដាក់ជំនួសរួចល័ក្ខខ័ណ្ឌបន្ថែម ដែលត្រូវដាក់នេះត្រូវចងភ្ជាប់តាមផ្លូវច្បាប់ និងត្រូវប្រតិបត្តិតាមដោយអ្នកកាន់អាជ្ញាប័ណ្ណ និងត្រូវចូលជាធរមានដូចបានកំណត់ក្នុងអាជ្ញាប័ណ្ណ ដូច្នេះដែរ ។ | 3. EAC may, instead of revoking any License, permit it to remain in force subject to such further terms and conditions as considered fit to impose and any further terms or conditions imposed shall be binding upon and be observed by the Licensee, and be of like force and effect as if they were contained in the License. |

# ឧបសម្ព័ន្ធទី៤
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ
## SCHEDULE 4

## OWNERSHIP OF LICENSEE

| | |
|---|---|
| ១- អ្នកកាន់អាជ្ញាប័ណ្ណរួមមានម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីក្នុងក្រុមហ៊ុន វ៉ឌ្ឍនៈ ប្រូបភើធី លីមីតធីត ដែលបានបែងចែកជា ១០០០ ភាគហ៊ុន ដូចខាងក្រោមៈ<br>(ក) លោក សំ អាង មានចំនួន ៥០០ ភាគហ៊ុន ពីលេខ ០០០១ ដល់លេខ ០៥០០<br>(ខ) លោកស្រី ឈុន លាង មានចំនួន ៥០០ ភាគហ៊ុន ពីលេខ ០៥០១ ដល់លេខ ១០០០ | 1. The licensee has the following registered owners of the **Vattanac Properties LTD** with the 1000 shares are:<br>(a) Mr. **SAM ANG**: 500 shares from 0001 to 0500<br>(b) Mrs. **CHUN LEANG**: 500 shares from 0501 to 1000 |
| ២- យោងតាមមាត្រា ៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគ ហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ ក្នុងករណីជាក់លាក់ណាមួយដើម្បីជាផលប្រយោជន៍សាធារណៈ អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីសម្រេចអនុញ្ញាតឱ្យបាន ។ | 2. Refer to Article 45 of the Electricity Law of the Kingdom of Cambodia, the above registered owners shall not own shares in or have any other direct financial interests in any other licensee without written permission from EAC. EAC may permit in specific cases in public interest. |